ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ
សូមជម្រាបជូន
ឯកឧត្តម ហ ុ ន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
ក្នុងពិធីបម្រើនៅឋានយុគម្រប់ ៤២ ឈានចូល ៤៣ឆ្នាំ

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជាទីគោរពស្រឡាញ់រាន!

ក្នុងវិការសង្គមមហានក្ខត្តឫក្ស ប្រកបដោយក្តីរីករាយក្រៃលន់ជាទីបំផុត នៃពិធីចម្រើនវន្ទាយុគម្រប់ ៤២ ឈានចូល ៤៣ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ណរកើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ខាងមុខនេះ: ពាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ សូមសម្តែងនូវសេចក្តីសោមនស្សរីករាយ និងសូមជូននូវសក្ខីភាពពរជ័យ ឫទ្ធិសួស្តី សិរីមង្គល វិបុលសុខ មហាប្រយោជ៍ ជូន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** សូមទទួលបាននូវសុខភាពល្អបរិបូណ៌ កម្លាំងមាំមួន បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំក្រសួងមុខងារសាធារណៈ ឱ្យមានការអភិវឌ្ឍរីកចម្រើនថ្មីៗបន្ថែមទៀត។

នាវិការសង្គមនសរីរាកាយនេះ: យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការកោតសរសើរដោយស្មោះស្ម័គ្រចំពោះ: **ឯកឧត្តម** ដែលជាវស្សជនបន្ថែមមួយរូប ពោរពេញដោយសមត្ថភាព ជាអ្នកដឹកនាំ ឈ្លាសវៃ ប៉ិនប្រសប់ និងមានការទទួលខុសត្រូវខ្ពស់ក្នុងការបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមបម្រើឱ្យឧត្តមប្រយោជ៍ន៍ ជាតិ **សាសនា ព្រះមហាក្សត្រ** ព្រមជាមួយគ្នានេះ: ក្រោមការដឹកនាំរបស់ **ឯកឧត្តម** បានធ្វើឱ្យក្រសួងមុខងារសាធារណៈ: នៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវសិទ្ធផលជាបន្តបន្ទាប់ស្ទាវ៉ាក្រស់សម្ហាល ជាពិសេសការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការធ្វើកំណែទម្រង់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានរួមចំណែកដល់ការលើកកម្ពស់ប្រសិទ្ធភាពការងារ ស្របតាមបំណងប្រាថ្នាដែលប្រជាជនកម្ពុជាចង់បាន។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំ និងភរិយា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាអារក្ស ទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះប្រាំនូវសក្ខីភាពពរជ័យ សិរីមង្គល វិបុលសុខ ជូនចំពោះ: **ឯកឧត្តម** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវកុសលទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីរៀងរាគរយើយ ។

សូម **ឯកឧត្តម ហ ុ ន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** ទទួលនូវការគោរពពាប់អានអំពីខ្ញុំ។

ថ្ងៃអង្គារ ១០រោចនៃ ក្តីកា ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២៥
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ទៀ សីហា

វិថីក្រសួងការពារ សង្កាត់មិត្តភាព ខណ្ឌឫស្សីកែ រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៨ email: generalsec@mod.gov.kh

ឯកឧត្តម ហ ុ ន ម៉ានី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

អរគុណសន្ធិភាព! អរគុណនយោបាយឈ្នះឈ្នះ!